## ១-លក្ខណៈទូទៅ

ដំណាំល្មុតគឺជាប្រភេទដើមឈើធំ និង មានស្លឹកខៀវស្រងាត់ពេញមួយរដូវ។ វាមានកម្ពស់រហូតដល់៣០ម និងមានអង្កត់ផ្ចិត១.៥ម៉ែត្រ ។ ការដាំដុះអាចប្រែប្រួលពីចន្លោះ ៩ ទៅ ១៥ ម៉ែត្រអាស្រ័យទៅនឹង (គំលាតដើម) លក្ខណៈភូមិសាស្ត្រ ។ មែករបស់វាបែកមែកសាខា ហើយគល់របស់វាមានរាងជាស៊ីឡាំងទ្រវែង ជាពិសេសដើមដុះនៅទោលតែឯង។ សម្បុករបស់វាមានសម្បុរត្នោតចាស់ និងមានស្នាមប្រេះតូចៗ។ ឫសរបស់វា ជាប្រភេទប្រព័ន្ធឫសសាំញ៉ាំ។ ស្លឹករបស់វាជាប្រភេទស្លឹកឆ្លាស់ ហើយតម្រៀបគ្នានៅលើ shoot tips ។

## ២.ការធ្វើចំណាត់ថ្នាក់របស់រុក្ខជាតិ

សណ្ឋាន :Sapotaceae

អំបូរ :Manilkara/Achras

ប្រភេទ :Zapota

ឈ្មោះវិទ្យាសាស្ត្រ :Manilkara Zapota / Achras Zapota

ឈ្មោះអង់គ្លេស :Sapodilla, Naseberry, Sapota ។ ទីកន្លែងដាំដុះតំបន់ត្រូពិច។ :

## ៣.លក្ខណៈរូបសាស្ត្រ

ក.កម្ពស់ដើម អាចឈានដល់កម្ពស់៣០ម បែកមែកសាខាពណ៌ត្នោតចាស់ ការលូតលាស់យឺតមានជ័រពណ៌ស ។

ខ.ស្លឹកៈបណ្ដោយចាប់ពី៣,៥ស.មដល់១៥ស.ម ទទឹង១,៥ស.ម ដល់ ៧ស.មស្លឹកខ្ចីមានពណ៌លឿងត្នោតខ្ចី ស្លឹកចាស់មានពណ៌ត្នោតចាស់ ស្លឹកមានលក្ខណៈរលោងក្រាស់ជាប្រភេទស្លឹកឆ្លាស់។

គ.ផ្កាៈ ពេលវេលាចេញផ្កា គឺចេញស្ទើររាល់ខែផ្កាមានលក្ខណៈជាចង្កោម ហើយមានពណ៌សមានរាងដូចជួង និងមាន៦ត្របក។

ឃ.ផ្លែៈ មាននៅខែមេសា និងសីហាមានរាងមូលនិងទ្រវែងមានប្រវែងចាប់ពី៣ស.មដល់៨ស.ម ។ នៅពេលទុំផ្លែមានពណ៌លឿងត្នោត សាច់ខាងក្នុងមានពណ៌លឿងត្នោតមានរសជាតិផ្អែមឆ្ងាញ់។

ង.គ្រាប់ៈ នៅក្នុងមួយផ្លែមានគ្រាប់ពី ២-៥គ្រាប់ រាងសំប៉ែតទ្រវែង ស្រួចសងខាងបណ្ដោយគ្រាប់ប្រវែង២ស.ម ទទឹងគ្រាប់មានប្រវែង ចាប់ពី១ស.ម ដល់ ២ស.ម សំបកគ្រាប់មានភាពរឹងរលោងពណ៌ក្រម៉ៅឬពណ៌ខ្មៅ។

## ៤. ពូជល្មុត

ក.ពូជធម្មតា ឬល្មុតណាំងបាយស្រោះ ផ្លែវាធំល្មមរាងទ្រវែងផ្លែ៤ទៅ៥ដងក្នុងមួយឆ្នាំ។

ខ.ល្មុតណាំង ឬល្មុតណាំងថ្ម ឬល្មុតថ្មៈ ផ្លែល្អិតៗ ប៉ុន្តែរឹងវាផ្លែ២ទៅ៣ដងក្នុងមួយឆ្នាំ ។

គ.ល្មុតពូជចឹកកាយ៉ាំង ឬល្មុតតាខ្មៅៈ ផ្លែធំៗ វាផ្លែ៤ទៅ៥ដងក្នុងមួយឆ្នាំ ប៉ុន្តែពុំសូវមានរសជាតិឆ្ងាញ់ទេ។ គេនិយមប្រើប្រាស់វានៅក្នុងពិធីមង្គលការនិងបុណ្យទានផ្សេងៗ។

ឃ.ល្មុតណាំងប៉ែន ឬល្មុតណាំងខ្សាច់ៈ ផ្លែមានរាងដូចផ្លែចាន់ប៉ែន សាច់វាទន់ជ្រាកៗបន្តិច ផ្លែវាធំជាងល្មុតធម្មតាបន្តិច វាផ្លែ៤ទៅ៥ដងក្នុងមួយឆ្នាំ។

## ៥. លក្ខខណ្ឌដី

ដំណាំល្មុត អាចដាំបាននៅលើប្រភេទដីកណ្ដេង ដីឥដ្ឋ ដីខ្សាច់ ដីអាស៊ីត ដីបាស ដីល្បាយខ្សាច់ មានជីជាតិ និង ស្រោះទឹកPH ចាប់ពី៥,៥ ដល់ ៦ ។

## ៦. អាកាសធាតុ

ដំណាំល្មុតអាចដាំបាន គឺអាកាសធាតុតំបន់ត្រូពិច ចំពោះដើមចាស់វាអាចទ្រាំបាននៅសីតុណ្ហភាពដក៣,៣៣ អង្សាសេ ដល់ ដក២,២អង្សាសេ។

## ៧. ការរៀបចំដី និងរណ្ដៅដាំល្មុត

- យើងត្រូវភ្ជួរហាលដីទុកចោលចំនួន ១ ទៅ១ខែកន្លះសិន ដើម្បីអោយងាប់សត្វល្អិតនិង ស្មៅរលួយបានល្អ ។ យើងត្រូវភ្ជួរដីមួយលើកទៀតនៅពេលដែលជិតដាំកូនល្មុត។
- យើងត្រូវទាញខ្សែអោយត្រង់ ដើម្បីងាយស្រួលក្នុងការដាំដំណាំផ្សេងទៀត ។
- ចន្លោះពីដើមមួយទៅដើមមួយមានប្រវែង៥ម៉ែត្រ
- កាប់រណ្ដៅទំហំ៤តឹកបួនជ្រុង និងជំរៅ៤តឹក កាប់យកអាចម៍ដីចេញពាក់កណ្ដាលរណ្ដៅ រួចទើបកាប់បំផុសអាចម៍ដី ដែលនៅសល់ឲ្យម៉ដ្ឋ រួចដាក់លាយជាមួយជីអាចម៍គោពុកផុយល្អ ។ ត្រូវហាលរណ្ដៅទុកចោល២ទៅ៣ថ្ងៃមុនដាំ។

## ៨.ការដាំកូនល្មុត

- យើងត្រូវយកមែកល្មុត(មែកសាក) នៅក្បែររណ្ដៅជាមុនសិន។
- យកមែកល្មុតសាកមកត្រាំទឹកឲ្យសើមបន្តិច។
- ស្រាយកញ្ចប់ផ្លាស្ទិចចេញយឺតៗ ដោយថ្នមៗ និង

ប្រុងប្រយ័ត្នជានិច្ច ដោយកុំឲ្យបែកអាចម៍ដី និងដាច់ឫសល្មុតដែលបណ្តាលអោយវាងាប់បាន។

•ត្រូវដាក់មែកល្មុតសាកចូលទៅក្នុងរណ្តៅថ្មមៗ ដៃម្ខាងទៀតត្រូវប្រមូលអាចម៍ដីលុបរណ្តៅ ដោយ ប្របាច់ដីអោយបានតូចៗលុបរោយបំពេញរណ្តៅ ដោយកប់ដីឫសកំពស់១ធ្នាប់ដៃ ហើយនៅសល់ប្រហែល២ធ្នាប់ដៃទៀត ទើបរោយអាចម៍ដីស្មើនឹងមាត់រណ្តៅ។

•យើងមិនត្រូវជាន់បង្ហាប់ដី នៅក្នុងរណ្តៅនោះទេ។

•យើងត្រូវបោះបង្គោល២ ឬ ៣ដើមចងភ្ជាប់នឹងមែកល្មុត ដើម្បីឲ្យវាមានជំហរត្រង់និងរឹងមាំ។

•យើងត្រូវស្រោចទឹកឲ្យសើមល្មម ដោយយកដៃទទះទឹកដូចស្រោចលើកូនស្លែ។

## ៩. ការថែទាំដើមល្មុត

•ដើមល្មុតដែលទើបដាំរួច មិនត្រូវប៉ះពាល់ ឬបេះត្រួយស្លឹកឬកាច់មែកបានទេ ហើយក៏មិនត្រូវអោយសត្វពាហនៈញាំញីបានឡើយ នាំឲ្យដើមល្មុតងាប់ ដោយសារតែឫសវាងាយដាច់រលាត់ណាស់។

•ត្រូវតាមដាន និង កម្ចាត់ដង្កូវស៊ីដើមល្មុតចេញ។ ដង្កូវនេះវាស៊ីតែមែក ឬ ដើមល្មុតទេ។ វាស៊ីពីលើចុះមកក្រោម វាអាចរស់នៅក្នុងមែកល្មុតបានប្រហែល៤ទៅ៥សប្តាហ៍។

•បើសង្កេតឃើញមានអាចម៍ដង្កូវ នៅតាមមែកល្មុត យើងត្រូវឆ្កឹះសំបកមែករហូតដល់ឃើញដង្កូវ និងសម្លាប់វាចោល។

### ក.ការស្រោចស្រព

កូនដែលទើបនឹងដាំត្រូវការទឹករហូតដល់២ ទៅ៣ឆ្នាំ ធ្វើការស្រោចស្រពខ្លាំងនៅដំណាក់កាលចេញផ្កា និងដំណាក់កាលផ្លែ។

### ខ.ការដាក់ជី

ដើមមិនទាន់ផ្តល់ផ្លែត្រូវដាក់ជី20-20-15+TE ២៥០-៥០០ក្រាមក្នុងមួយដើម ក្នុងមួយឆ្នាំ។ ដើមដែលអាចផ្តល់ផ្លែត្រូវផ្តល់ជី20-20-15+2TE ៥០០ក្រាមដើម/ និងដាក់ពីរដងក្នុងមួយឆ្នាំ។

## ១០.ការប្រមូលផលផ្លែល្មុត

ចាប់ពី៣ឆ្នាំឡើងទៅ យើងអាចប្រមូលផលបានខ្លះៗ។ ចាប់ពី៥ឆ្នាំឡើងទៅ ក្នុងមួយដើមយើងអាចប្រមូលផលបាន១០០គីឡូក្រាមក្នុងមួយឆ្នាំ។ ជាធម្មតាផ្លែល្មុតចាស់ អាចបេះយកមកបន្ទុំបានដោយសង្កេតមើលសំបកផ្លែរលោង ឬ យើងកោសលើផ្លែវាមានពណ៌លឿងខ្នោត។



**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ខេត្តកណ្តាល**

## ព័ត៌មានបច្ចេកទេសកសិកម្ម



# ដំណាំល្មុត

Sapodilla




រៀបចំដោយ: លោក អ៊ិន ចាន់យ៉ារិទ្ធ អនុប្រធានការិយាល័យនីតិកម្មកសិកម្ម នៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល។